# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**

លេខៈ ០៦ រកព.ប្រក

## ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះមជ្ឈមណ្ឌល តម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន(រ.ក.ព.) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់មជ្ឈមណ្ឌល។

## ជំពូកទី២
## រចនាសម្ព័ន្ធមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

**ប្រការ២ .-**

មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែនមានការិយាល័យចំណុះចំនួន២(ពីរ) រួមមាន៖

- ការិយាល័យចរាចរឯកសារ
- ការិយាល័យកំណត់ត្រានិងបណ្ណសារ។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែននៃ រ.ក.ព. ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានការិយាល័យ១(មួយ)រូប និងមានអនុប្រធានការិយាល័យមួយចំនួន តាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី១
## ភារកិច្ចការិយាល័យចំណុះមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

**ប្រការ៤ .-**

ការិយាល័យចរាចរឯកសារមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពរបស់ការិយាល័យចរាចរឯកសារ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- សម្របសម្រួលប្រមូលឯកសារ ផែនទី និងទិន្នន័យព្រំដែនពីអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះ រ.ក.ព. ដើម្បីប្រគល់ជូនការិយាល័យកំណត់ត្រានិងបណ្ណសារ
- ស្រាវជ្រាវនិងលើកសំណើប្រមូលឯកសារ ផែនទី និងទិន្នន័យព្រំដែន ពីក្រសួង ស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ ជូនប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- រៀបចំបែបបទនីតិវិធីស្នើសុំចូលមើល ពិនិត្យ និងប្រើប្រាស់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

- សម្របសម្រួលរាល់សំណើសុំចូលមើល ពិនិត្យ និងប្រើប្រាស់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- ចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងឯកសារ ផែនទី និងទិន្នន័យព្រំដែន
- ចូលរួមធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ណសារតាមប្រព័ន្ធព័ត៌មានវិទ្យារបស់មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- សម្របសម្រួលផ្តល់ឯកសារនិងទិន្នន័យព្រំដែនជូនថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងអង្គភាពចំណុះ តាមការស្នើសុំ ដោយសហការជាមួយការិយាល័យកំណត់ត្រានិងបណ្ណសារ
- បំពេញកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុប្រចាំថ្ងៃរបស់ការិយាល័យចរាចរឯកសារ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែនប្រគល់ជូន។

**ប្រការ៥ .-**

ការិយាល័យកំណត់ត្រានិងបណ្ណសារមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យកំណត់ត្រានិងបណ្ណសារ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- ចូលរួមរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តស្របតាមបទដ្ឋានបច្ចេកទេស សម្រាប់រក្សាទុកឯកសារ ផែនទី និងទិន្នន័យព្រំដែនឱ្យបានត្រឹមត្រូវនិងច្បាស់លាស់ ប្រកបដោយសុវត្ថិភាព គុណភាពខ្ពស់ និងយូរអង្វែង ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ទទួល ចងក្រង គ្រប់គ្រង តម្កល់ទុក ថែរក្សា និងថែទាំឯកសារ ផែនទី និងទិន្នន័យព្រំដែនច្បាប់ដើម របស់ រ.ក.ព.
- ធ្វើឌីជីថលភាវូបនីយកម្ម និងគ្រប់គ្រងឯកសារ ផែនទី និងទិន្នន័យព្រំដែនតាមប្រព័ន្ធព័ត៌មានវិទ្យា
- ចូលរួមរៀបចំនិងធ្វើទំនើបកម្មប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា សម្រាប់គ្រប់គ្រង ថែរក្សា និងថែទាំឯកសារ ផែនទី និងទិន្នន័យព្រំដែននៃ រ.ក.ព. ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- រៀបចំវាយតម្លៃនិងធ្វើចំណាត់ថ្នាក់ប្រភេទឯកសារ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ស្វែងរកនិងផ្តល់ឯកសារនិងទិន្នន័យជូនថ្នាក់ដឹកនាំ រ.ក.ព. និងអង្គភាពចំណុះ រ.ក.ព.
- រៀបចំ គ្រប់គ្រង និងធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវឯកសារ ផែនទី និងទិន្នន័យព្រំដែនរបស់រ.ក.ព.
- រៀបចំកម្មវិធីកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីការិយាល័យកំណត់ត្រានិងបណ្ណសារ
- រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងឯកសារ ផែនទី និងទិន្នន័យព្រំដែន
- បំពេញកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុប្រចាំថ្ងៃរបស់ការិយាល័យកំណត់ត្រានិងបណ្ណសារ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែនប្រគល់ជូន។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន ប្រធានវិទ្យាស្ថានជាតិកិច្ចការព្រំដែន ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពចំណុះ រ.ក.ព. ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០៦ រកគ.ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២៤
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
អង្គការលេខនៃរចនាសម្ព័ន្ធរបស់ការិយាល័យចំណុះមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

**មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន**

- ការិយាល័យចរាចរឯកសារ
- ការិយាល័យកំណត់ត្រានិងបណ្ណសារ